**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ: ២០៦ សជណ.ប.ស្ក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងការអភិរក្សព្រៃឈើតំបន់ព្រៃឡង់

ក្រសួងបរិស្ថាន មានកិត្តិយស សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណៈជនទាំងអស់ មេត្តាជ្រាបថា ក្រសួងបរិស្ថាននឹងមានរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងការអភិរក្សព្រៃឈើតំបន់ព្រៃឡង់ រវាងក្រសួងបរិស្ថាន អង្គការអភិរក្សអន្តរជាតិ (Conservation International) និងក្រុមហ៊ុនMitsui&Co.,LTD. នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង២:៣០ នាទីរសៀល នៅទីស្តីការក្រសួងបរិស្ថាន សាលប្រជុំ ម៉ុក ម៉ារ៉េត ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ មានគោលបំណងបង្ហាញពីការប្តេជ្ញាចិត្តចូលរួមចំណែករបស់ក្រុមហ៊ុនឯកជនអន្តរជាតិ និងអង្គការដៃគូអភិវឌ្ឍន៍នានា ក្នុងការងារការពារ និងអភិរក្សធនធានព្រៃឈើរបស់កម្ពុជា នៅក្រោមក្របខណ្ឌយន្តការឥណទានកាបូនរួមគ្នា (Joint Crediting Mechanism-JCM) ដែលជាយន្តការទ្វេភាគីថ្មីមួយរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន ក្នុងភាពជាដៃគូជំរុញការអភិវឌ្ឍន៍បៃតង បញ្ចេញកាបូនតិច នៅកម្ពុជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មានដោយអនុគ្រោះ។

ថ្ងៃសុក្រ ១ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៨


*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖*

លោក អ៊ុយ កាម៉ាល់
អនុប្រធាននាយកដ្ឋាន
លេខទូរស័ព្ទ៖ ០១២ ២៨៣ ៩៥៦
អ៊ីម៉ែល៖ kamaluy@hotmail.com

កញ្ញា ខូវ បុប្ផារ័ត្ន
មន្ត្រីលេខាធិការដ្ឋានJCM
លេខទូរស័ព្ទ៖ ០៧៨ ៦៦៣ ៦៨៨
អ៊ីម៉ែល៖ khovbopharoth@gmail.com